Australian Government

COVID-19 VACCINATION

# ដូសវ៉ាក់សាំង COVID-19 ទីបួន

ថ្ងៃទី 08 ខែកក្កដា ឆ្នាំ 2022

រដូវរងារជាញឹកញាប់នាំមកនូវការឆ្លងកាន់តែច្រើនពីវីរុសផ្លូវដង្ហើមដូចជា COVID-19។ ដើម្បីផ្តល់ការការពារបានច្រើនបំផុតប្រឆាំងទល់នឹង COVID-19, ដូសជំរុញបន្ថែម ឬដូសវ៉ាក់សាំង COVID-19 ទីបួនត្រូវបានណែនាំសម្រាប់មនុស្សដែលប្រឈមហានិភ័យកាន់តែខ្ពស់នៃជំងឺធ្ងន់ធ្ងរពី COVID-19។ នេះនឹងជាដូសវ៉ាក់សាំង COVID-19 ទីប្រាំ សម្រាប់មនុស្សដែលមានប្រព័ន្ធភាពស៊ាំខ្សោយធ្ងន់ធ្ងរ។

អ្នកគួរតែទទួលដូសវ៉ាក់សាំង COVID-19 ទីបួន ប្រសិនបើអ្នក៖

- មានអាយុ 50 ឆ្នាំ ឬអាយុចាស់ជាងនេះ
- អ្នករស់នៅកន្លែងថែទាំមនុស្សចាស់ ឬកន្លែងថែទាំជនពិការ

ដូសជំរុញបន្ថែមក៏ត្រូវបានណែនាំសម្រាប់មនុស្សដែលមានអាយុ 16 ឆ្នាំ ឬអាយុច្រើនជាងនេះដែល៖

- មានប្រព័ន្ធភាពស៊ាំខ្សោយ
- មាន ឬបានរស់រានមានជីវិតពីជំងឺជាក់លាក់មួយចំនួន
- មានជំងឺដែលប្រព័ន្ធភាពស៊ាំវាយប្រហារខុសទៅលើរាងកាយដែលតម្រូវឱ្យមានការព្យាបាល
- មានជំងឺធ្ងន់ធ្ងរ ឬរ៉ាំរ៉ៃដែលប៉ះពាល់ដល់សួត ថ្លើម តម្រងនោម ខួរក្បាល ឬបេះដូងរបស់អ្នក
- មានជំងឺទឹកនោមផ្អែមដែលតម្រូវឱ្យមានការពិសាថ្នាំ
- មានពិការភាពដោយមានសេចក្តីត្រូវការសុខភាពសំខាន់ ឬស្មុគស្មាញ
- មានទម្ងន់លើស ឬមិនគ្រប់ទម្ងន់ខ្លាំង។

មនុស្សដែលមានអាយុ 30 ឆ្នាំ ទៅ 49 ឆ្នាំ ក៏អាចទទួលដូសទីបួន ប្រសិនបើពួកគេជ្រើសរើស។

សូមនិយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើអ្នកមិនប្រាកដថាអ្នកត្រូវទទួលដូសទីបួនឬអត់។

អ្នកអាចទទួលដូសវ៉ាក់សាំង COVID-19 ទីបួន ប្រសិនបើវាបានមានរយៈពេលយ៉ាងហោចណាស់ **3 ខែ** ចាប់តាំងពីដូសជំរុញរបស់អ្នក។

អ្នកអាចទទួលការចាក់វ៉ាក់សាំង COVID-19 នៅពេលព្រមជាមួយគ្នានឹងការចាក់វ៉ាក់សាំងគ្រុនផ្តាសាយបាន។

ប្រសិនបើអ្នកបានធ្វើតេស្តរកឃើញ COVID-19 វិជ្ជមានក្នុងពេលថ្មីៗនេះ នោះអ្នកគួរតែរង់ចាំរយៈពេល **3 ខែ** នៅមុនពេលទទួលដូសវ៉ាក់សាំង COVID-19 បន្ទាប់របស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល www.health.gov.au ឬហៅទូរសព្ទទៅ National Coronavirus Helpline (ខ្សែទូរសព្ទជំនួយវីរុសកូរ៉ូណាថ្នាក់ជាតិ) តាមលេខ 1800 020 080។ ជ្រើសរើសជម្រើសទី 8 សម្រាប់សេវាបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ។